

# ព្រះរាជាណាចក្រកម្ពុជា

## ប្រព័ន្ធអប់រំនៅកម្ពុជា(1)

- ផ្ទៃដី:181,035 km$^2$(ពាក់កណ្ដាលជប៉ុន)
- ប្រជាជន:1,530ម៉ឺននាក់(ជម្រឿនប្រជាជន, ឆ្នាំ2019)
- សាសន៍:ខ្មែរ 94%, ចិន3%, វៀតណាម3%
- ភាសា:ខ្មែរ
- សាសនា:ព្រះពុទ្ធសាសនា95% (ជនជាតិភាគតិចកាន់សាសនាអ៊ីស្លាម)
- អាយុជីវិតមធ្យម:បុរស 67.23ឆ្នាំ, ស្ត្រី 72.75ឆ្នាំ(WHO, ឆ្នាំ2019)
- អត្រាអក្ខរកម្មនៃមនុស្សពេញវ័យ:84%(ធនាគារពិភពលោក, ឆ្នាំ2021)

ក្នុងចំណោមអនិកជននៅជប៉ុនដែលពាក់ព័ន្ធនឹងកម្ពុជា (លើកលែងអ្នកស្នាក់នៅរយៈពេលខ្លី) អ្នកជំនាញពិសេស និងកម្មសិក្សាការីហ្វឹកហ្វឺនជំនាញដែលមិនអាចយកគ្រួសារមកជាមួយ មាន66% រីឯអ្នកមានសិទ្ធិនៅអចិន្ត្រៃយ៍ និងអ្នកមានសិទ្ធិស្នាក់នៅ ព្រមទាំងសហព័ទ្ធជនជាតិជប៉ុន ឬអ្នកមានសិទ្ធិនៅអចិន្ត្រៃយ៍ជាអាទិ៍មាន 15% (ក្រសួងកិច្ចការផ្ទៃក្នុងនិងទូរគមនាគមន៍ នាយកដ្ឋានស្ថិតិ, មិថុនា 2022)។ ដោយសារតែកុមារដែលមានអាយុចូលសាលា រស់នៅរយៈពេលវែងគួរសម ដូច្នេះហើយ គេរំពឹងថា មានការណែនាំកុមារដោយផ្អែកលើចក្ខុវិស័យមធ្យមនិងវែង។

### ប្រព័ន្ធសាលា និង លក្ខណៈសម្បត្តិ-សញ្ញាប័ត្រដែលអាចទទួលបាន

- ការអប់រំតាមកាតព្វកិច្ចគឺបឋមសិក្សា 6ឆ្នាំ និងមធ្យមសិក្សាបឋមភូមិ 3ឆ្នាំ សរុប 9ឆ្នាំ ដូចជប៉ុនដែរ។
- នៅក្រោមការគ្រប់គ្រងនៃរបបផ្តាច់ការនៅចុងទស្សវត្សរ៍1970 គេមិនទទួលស្គាល់ការអប់រំ ហើយបញ្ញវន្តជាច្រើន រួមទាំងគ្រូ ត្រូវបានសម្លាប់។ ក្រោយការដួលរលំនៃរបបនេះ កម្ពុជាបានរៀបចំប្រព័ន្ធអប់រំឡើងវិញ តែគុណភាពគ្រូនៅទាប គ្រឿងសម្ភារៈសិក្សា និងអាគារសាលាជាដើម ក៏នៅខ្វះ។
- អត្រានៃការបញ្ចប់ការសិក្សានៅឆ្នាំ2020～21 នៃបឋមសិក្សាគឺ 87.4%, នៃមធ្យមសិក្សាបឋមភូមិគឺ 48.1% ដូច្នេះគឺទាប កុមារភាគច្រើន មិនបានបញ្ចប់ការអប់រំតាមកាតព្វកិច្ចទេ។(ក្រសួងអប់រំយុវជននិងកីឡា, ឆ្នាំ2021) ។

| | សាលាមត្តេយ្យជាដើម | សាលាមត្តេយ្យ | (3ឆ្នាំ～6ឆ្នាំ) |
|---|---|---|---|
| ការអប់រំតាមកាតព្វកិច្ច | សាលាបឋមសិក្សា | ឆ្នាំទី1 | (6～7ឆ្នាំ) |
| | | ឆ្នាំទី2 | (7～8ឆ្នាំ) |
| | | ឆ្នាំទី3 | (8～9ឆ្នាំ) |
| | | ឆ្នាំទី4 | (9～10ឆ្នាំ) |
| | | ឆ្នាំទី5 | (10～11ឆ្នាំ) |
| | | ឆ្នាំទី6 | (11～12ឆ្នាំ) |
| | អនុវិទ្យាល័យ | ឆ្នាំទី7 | (12～13ឆ្នាំ) |
| | | ឆ្នាំទី8 | (13～14ឆ្នាំ) |
| | | ឆ្នាំទី9 | (14～15ឆ្នាំ) |
| | វិទ្យាល័យ-សាលាហ្វឹកហ្វឺនបច្ចេកទេស | ឆ្នាំទី10 | (15～16ឆ្នាំ) |
| | | ឆ្នាំទី11 | (16～17ឆ្នាំ) |
| | | ឆ្នាំទី12 | (17～18ឆ្នាំ) |
| | មហាវិទ្យាល័យ<br>សាលាហ្វឹកហ្វឺនបច្ចេកទេស<br>សាលាគរុកោសល្យ<br>(មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ, មជ្ឈមណ្ឌលគរុកោសល្យជាតិ) | | |

★សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ

★សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ

★សញ្ញាប័ត្រ ស្ថាប័នអប់រំជំនាញបច្ចេកទេស,3ឆ្នាំ បន្ទាប់ពីបានបញ្ចប់អនុវិទ្យាល័យ

★បរិញ្ញាប័ត្ររង ★បរិញ្ញាប័ត្រ

★អនុបណ្ឌិត ★បណ្ឌិត

★សញ្ញាប័ត្រ (ស្ថាប័នអប់រំជំនាញបច្ចេកទេស, 2～3ឆ្នាំ បន្ទាប់ពីបញ្ចប់ការសិក្សានៅវិទ្យាល័យ)

★សញ្ញាប័ត្រគ្រូ

> ឆ្នាំសិក្សាចាប់ផ្តើមពីខែ១០ គឺខុសពីជប៉ុន ក៏ប៉ុន្តែអាយុត្រូវចូលឆ្នាំសិក្សានីមួយៗគឺដូចជប៉ុនដែរ។

### បែបបទពេលចូលសាលា, ការកំណត់សាលាតាមតំបន់

- អ្នកអាណាព្យាបាលមានកាតព្វកិច្ចឱ្យកូនទៅសាលា។
- ជាគោលការណ៍ សាលាដែលត្រូវទៅ គឺត្រូវបានកំណត់ទៅតាមលំនៅដ្ឋាន។ ក៏ប៉ុន្តែ អាចសុំចូលសាលាផ្សេងដោយមូលហេតុភូមិសាស្ត្រ សេដ្ឋកិច្ច គុណភាពនៃការអប់រំជាដើមបាន។ បើសិនជាសាលាអាចទទួលយក អាចចូលសាលាដែលចង់ឱ្យចូលនោះបាន។
- បើសិនជាគ្រួសារណាមួយមានកូនអាយុ6ឆ្នាំ ឬយ៉ាងតិច5ឆ្នាំ10ខែ សាលានិងរដ្ឋបាលមូលដ្ឋាននឹងសហការគ្នា ធ្វើការជូនដំណឹងអំពីនីតិវិធីចុះឈ្មោះចូលរៀន។

> នៅក្នុងគ្រួសារណាមួយ បើសិនជាមានក្មេងមិនចូលសាលា អ្នកដឹកនាំក្នុងសហគមន៍នឹងណែនាឱ្យអ្នកអាណាព្យាបាលយកកូនទៅសាលា។

### ថ្លៃសាលា

- ច្បាប់ស្តីពីការអប់រំ(2017)មានចែងថា សាលាបឋមសិក្សានិងសាលាអនុវិទ្យាល័យរដ្ឋ(អំឡុងពេលនៃការអប់រំតាមកាតព្វកិច្ច)មិនតម្រូវឱ្យបង់ថ្លៃសាលាទេ។ ក្នុងច្បាប់នេះអត់មានចែងអំពីថ្លៃសាលាវិទ្យាល័យទេ តែជាក់ស្តែង វិទ្យាល័យរដ្ឋគឺឆ្នាំទី១០ ដល់ទី១២ ពុំតម្រូវឱ្យបង់ទេ។
- សាលាឱ្យខ្ចីសៀវភៅសិក្សា តែឯកសណ្ឋាន ឬសម្ភារៈសិក្សា ត្រូវតែទិញខ្លួនឯង។ ម្យ៉ាងទៀត ចំពោះសាលាដែលមានថ្នាក់ក្រៅកម្មវិធីសិក្សា ដូចជាតន្ត្រី ភាសាបរទេស កីឡា សិល្បៈ កុំព្យូទ័រ វិទ្យាសាស្ត្ររូបូ ជាអាទិ៍ អ្នកអាណាព្យាបាលត្រូវទទួលបន្ទុកលើចំណាយជួលគ្រូឯកទេសក្រៅពីគ្រូប្រចាំសាលា។
- ក្រៅពីនេះ ដើម្បីរៀបចំកម្មវិធីផ្សេងៗ ឬសាងសង់បង្គន់នៅសាលា មានសាលាខ្លះទាមទារឱ្យអ្នកអាណាព្យាបាលចូលវិភាគទាន។ មានករណីខ្លះដែលអ្នកអាណាព្យាបាលបានផ្តួចផ្តើមគំនិតចូលវិភាគទានសម្រាប់គោលបំណងជាក់លាក់អ្វីមួយ ដើម្បីលើកកំពស់គុណភាពអប់រំ។

### លក្ខខណ្ឌនៃការចូលរៀន

- អនុវិទ្យាល័យ : បញ្ចប់ការសិក្សានៅបឋមសិក្សា
- វិទ្យាល័យ : ជាប់ក្នុងការប្រឡងយកសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិទូទាំងប្រទេស
- មហាវិទ្យាល័យ-សាលាហ្វឹកហ្វឺនជំនាញបច្ចេកទេស : ជាប់ក្នុងការប្រឡងយកសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិទូទាំងប្រទេស
- មជ្ឈមណ្ឌគរុកោសល្យភូមិភាគ : មានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិទូទាំងប្រទេស＋ជាប់ក្នុងការប្រឡងចូល
- មជ្ឈមណ្ឌលគរុកោសល្យជាតិ: មានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិទូទាំងប្រទេស＋ជាប់ក្នុងការប្រឡងចូល

> ពុំមានការប្រឡងបញ្ចប់បឋមសិក្សាទេ ឱ្យតែស្របនឹងលក្ខខណ្ឌ ដូចឆ្នាំទី១ ដល់ទី៥ គឺអាចបញ្ចបការសិក្សានៅបឋមសិក្សាបាន។

> រីឯមហាវិទ្យាល័យ និងសាលាហ្វឹកហ្វឺនជំនាញវិញ បើសិនជាជាប់ក្នុងការប្រឡងមធ្យមសិក្សាទុតិយភូមិទូទាំងប្រទេស នឹងមានលក្ខណៈសម្បត្តិចូល(មិនចាំបាច់ប្រឡងចូលទេ)

©2024 Japan International Cooperation Agency. All Rights Reserved

# ប្រព័ន្ធអប់រំនៅកម្ពុជា (2)

## ការចូលរៀនរបស់សិស្សពិការ

※និយមន័យនៃ "ការអប់រំជំនួយពិសេស" ឬ "ថ្នាក់ពិសេស" គឺខុសៗគ្នាទៅតាមប្រទេសនីមួយៗ។ ព័ត៌មានលំអិត សូមមើលសៀវភៅណែនាំស្ដីពីកាប្រើលទ្ធផលនៃការស្រាវជ្រាវអំពីប្រព័ន្ធអប់រំនៃប្រទេសនីមួយៗ។

នៅក្នុង "ច្បាប់ស្ដីពីការការពារនិងលើកកំពស់សិទ្ធិជនពិការ" (2009) មានចែងច្បាស់លាស់អំពីការការពារសិស្សពិការពេលចូលសាលា ហើយទស្សនៈនៅក្នុងនោះគឺ គេបានលើកឡើងនូវការអប់រំជាមួយគ្នា។ គឺត្រូវបង្កើតផែនការអប់រំដោយឡែកសម្រាប់កុមារពិការ ហើយត្រូវធ្វើការអប់រំទៅតាមតម្រូវការម្នាក់ដោយផ្អែកលើផែនការនោះ។

ក៏ប៉ុន្តែ ដោយសារតែបរិស្ថានមិនទាន់បានរៀបចំពេញលេញ ហើយសមត្ថភាពនិងការយល់ដឹងរបស់គ្រូក៏មានកម្រិត ហេតុនេះហើយបានជាមានករណីជាច្រើនដែលកុមារពិការទទួលនូវការអប់រំក្នុងបរិស្ថានផ្សេងគ្នា។ លើសពីនេះ យោងតាមការស្រាវជ្រាវខ្លះ គេរកឃើញករណីដែលអ្នកអាណាព្យាបាលមិនឱ្យកូនរបស់ខ្លួនទៅសាលា ឬក៏ឱ្យឈប់ពាក់កណ្ដាលទី (RTI International, ឆ្នាំ2018)។

- **បែបបទនៃការសុំចូលសាលា**

1) សមាជិកគណកម្មាធិការជួយសាលាដែលបានទទួលការបណ្ដុះបណ្ដាល, នាយកសាលា អ្នកជំនួយសុខភាពក្នុងភូមិត្រូវក្ដាប់ឱ្យបាននូវកុមារពិការក្នុងតំបន់របស់ខ្លួន។

2) បើសិនជាអ្នកអាណាព្យាបាលមិនទាក់ទងមក ឬមិនមកពិគ្រោះ អ្នកសម្របសម្រួលរបស់សាលាដែលកុមារនោះគប្បីចូលរៀន ត្រូវទៅផ្ទះកុមារនោះ ធ្វើការពិនិត្យអំពីពិការភាពនោះ។

3) ត្រូវធ្វើការបញ្ជាក់អំពីវិធីធ្វើដំណើរទៅសាលាជាមួយនឹងអ្នកអាណាព្យាបាល ហើយបើសិនជាមានការយល់ព្រមពីគាត់ឱ្យទៅសាលា ហើយឱ្យកុមារនោះចូលសាលាដែលមានការព្រមព្រៀងជាមួយនឹងអ្នកអាណាព្យាបាល

※តាមការពិត មានករណីជាច្រើនដែលមិនបានបំពេញបែបបទនេះឱ្យកុមារនោះចូលរៀន។

- **កន្លែងអប់រំកុមារពិការ**

**សាលាធម្មតា**

ដោយសារតែមានការរៀបចំបរិស្ថានមិនបានគ្រប់គ្រាន់ ហើយការយល់ដឹងនិងសមត្ថភាពរបស់គ្រូក៏មានកម្រិត ហេតុនេះហើយ មានការពិបាកនឹងសិក្សាជាមួយគ្នានៅក្នុងថ្នាក់ធម្មតា។ ឧទាហរណ៍ថា ទោះជាចូលសិក្សាថ្នាក់ធម្មតាជាមួយគ្នាក៏ដោយ ក៏មិនអាចទទួលបាននូវសេវាកម្មពេញលេញបានទេ។ ភាគច្រើន បានតែមួយកម្រិតអប្បបរមាប៉ុណ្ណោះ។

**សាលាចម្រុះ-ថ្នាក់ពិសេស**

គឺជាសាលាដែលផ្ដល់នូវការអប់រំតាមតម្រូវការនៃកុមារពិការ ហើយដែលគេបង្កើតក្នុងសាលាធម្មតា តែមានថ្នាក់ផ្សេងពីថ្នាក់ធម្មតា ទៅតាមតម្រូវការនៃពិការភាពរបស់កុមារ។ ភាគច្រើន ត្រូវបានបង្កើតឡើងដោយមានការចូលរួមជួយពី NGO។

**សាលាពិសេស**

គឺជាសាលាដែលផ្ដល់នូវការអប់រំទៅតាមពិការភាព ហើយខុសពីសាលាធម្មតា។ ភាគច្រើនៗតែ NGO ជាអ្នកដំណើរការ ហើយរដ្ឋាភិបាលជួយបំពេញប្រាក់ខែគ្រូៗ។

**ចំណុចដែលត្រូវប្រយ័ត្នក្នុងការណែនាំ**

- ស្ដីពី "ឧបសគ្គក្នុងការអភិវឌ្ឍ" រួមទាំងជម្ងឺអូទីហ្ស៊ីម និង ADHD ដែលជាទស្សនៈថ្មីគួរសម អ្នកអាណាព្យាបាលមិនសូវយល់ស៊ីជម្រៅទេ។ លើសពីនេះ មានករណីខ្លះដែលមិនបានដឹងថា មានជម្ងឺហ្នឹងថែមទៀត។
- ចាំបាច់ត្រូវប្រយ័ត្នអំពីឥទ្ធិពលនៃស្ថានភាពនៃការអប់រំ បរិស្ថានគ្រួសារ ប្រវត្តិនៃការចញ្ចឹមបីបាច់ ការអភិវឌ្ឍនៃភាសាកំណើត ជាដើម មុនមកជប៉ុន ទៅលើការអភិវឌ្ឍរបស់កុមារ។

# ខ្លឹមសារនៃការអប់រំនៅកម្ពុជា (1)

- នៅឆ្នាំ2016 ក្រសួងអប់រំ យុវជន និងកីឡាបានជ្រើសរើសកម្មវិធីថ្មី។ គេបានចែកសៀវភៅសិក្សាដែលធ្វើឡើងដោយផ្អែកលើកម្មវិធីថ្មីនេះជាបន្តបន្ទាប់។

## មុខវិជ្ជា(បឋមសិក្សាថ្នាក់ទី1～ថ្នាក់ទី6)

- មុខវិជ្ជាសំខាន់ៗនៅបឋមសិក្សាគឺភាសាខ្មែរ, គណិត, រូបវិទ្យា, សង្គម, ហាត់ប្រាណ។
- មានសាលាខ្លះ ពុំមានម៉ោងហាត់ប្រាណទេ តែនៅក្នុងកម្មវិធីថ្មី គឺជាមុខវិជ្ជាចាំបាច់។
- មុខវិជ្ជាសង្គម មិនមែនមានត្រឹមតែភូមិសាស្ត្រ ប្រវត្តិសាស្ត្រប៉ុណ្ណោះទេ គឺមានសីលធម៌ មុខវិជ្ជាមេផ្ទះ ដែលសាលានៅជប៉ុនមានដែរ។
- ការអប់រំភាសាអង់គ្លេស គឺចាប់ផ្ដើមពីឆ្នាំទី4។ ម្យ៉ាងទៀត ពីឆ្នាំទី4 ទៅ មានកម្មវិធីសិក្សាអំពីជីវិតក្នុងសហគមន៍ ដូចជា កសិកម្ម សេវាកម្ម សិប្បកម្មខ្នាតតូចៗ ដែលជាមុខវិជ្ជាវិជ្ជាជីវៈ និងជីវភាពរស់នៅផងដែរ។
- នៅក្នុងកម្មវិធីថ្មី ពីបឋមសិក្សាឆ្នាំទី4 ទៅ មានមុខវិជ្ជាបច្ចេកទេសព័ត៌មានដែរ។ ក៏ប៉ុន្តែមានតែសាលាបឋមសិក្សាមួយចំនួនតូចទេ ដែលមានកុំព្យូទ័រ ឬតាប្លេតឱ្យសិក្សា។

## ប្រព័ន្ធវាយតម្លៃ-ប្រព័ន្ធឡើងថ្នាក់

- សិស្សបឋមសិក្សាមួយចំនួនមិនអាចឡើងថ្នាក់បានដោយសារពិន្ទុ។ ការវិនិច្ឆ័យឱ្យឡើងថ្នាក់ ត្រូវបានធ្វើឡើងតាមរយៈការប្រឡងរាល់ខែ និងការប្រឡងចុងឆមាស។
- ចំពោះសិស្សដែលមិនមានពិន្ទុអាចឡើងថ្នាក់បាន នៅពេលវិស្សមកាល គេមានថ្នាក់រៀនប៉ប៉នបន្ថែម ហើយឱ្យប្រឡងម្ដងទៀត។ ក្រៅពីនេះ ចំពោះសិស្សរៀនខ្សោយពេក ក្នុង១អាទិត្យមានម៉ោងបង្រៀនបន្ថែមពិសេស 3ម៉ោងទៀត។
- នៅចុងឆមាស គេឱ្យតារាងពិន្ទុទៅសិស្ស។ នៅក្នុងនោះ មានកំណត់អំពីស្ថានភាពវត្តមាន ពិន្ទុនៃមុខវិជ្ជានីមួយៗ កិរិយាបទក្នុងសាលាជាដើម។ នៅពេលសាលាប្រគល់តារាងពិន្ទុនោះ អ្នកអាណាព្យាបាលត្រូវចុះហត្ថលេខា ហើយប្រគល់ទៅឱ្យសាលាវិញ។

- នៅសាលាបឋមសិក្សា សិស្សរៀនធ្លាក់មានប្រហែល6%(ធនាគារពិភពលោក, ឆ្នាំ2018)។
- សិស្សដែលសិក្សាបានចប់បឋមសិក្សាមានតែ80%ប៉ុណ្ណោះ(※)(ធនាគារពិភពលោក, ឆ្នាំ2019)។

(※)ភាគរយនៃសិស្សដែលបានចូលបឋមសិក្សាឆ្នាំទី1 រហូតដល់បានរៀនចប់ឆ្នាំទី6។

©2024 Japan International Cooperation Agency. All Rights Reserved

# ខ្លឹមសារនៃការអប់រំនៅកម្ពុជា (2)：កម្មវិធីសិក្សាអំពីគណិត

## តារាងស្តីពីខ្លឹមសារនៃការសិក្សាអំពីគណិតនៅបឋមសិក្សា(រៀបចំទៅតាមវិស័យសិក្សារបស់ជប៉ុន)

| វិស័យ/ឆ្នាំ | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ | ឆ្នាំទី៦ |
|---|---|---|---|---|---|---|
| លេខនិងគណិត | ● ដល់លេខ១០០ (លេខខ្មែរ) | ● ដល់លេខ 1000 (លេខបារាំង)<br>● លេខសេស, លេខគូ<br>● កាត់ខ្ទង់ (ខ្ទង់10) | ● ដល់លេខ10000<br>● កាត់ខ្ទង់ (ខ្ទង់100)<br>● ភាគលាភ ឬលេខអាចចែកដាច់ | ● ដល់លេខ 100000<br>● កាត់ខ្ទង់(ខ្ទង់1000) | ● ដល់លេខ 10លាន | ● ពីលេខ 10លានឡើងទៅ<br>● ចំនួនបឋម<br>● ភាគបែងរួមធំបំផុតនៃប្រភាគ, ពហុគុណតូចបំផុត |
| | ● វិធីបូកនិងវិធីដកនៃលេខ១ និង២ខ្ទង់ | ● វិធីបូក និងវិធីដក 2 និង3ខ្ទង់<br>● 9x9 (គុណនឹង 2 ដល់ 5 , នឹង 10)<br>● វិធីចែក (ចែកនឹង 2 ដល់ 5 , នឹង 10) | ● បូកនិងដកតាមការសរសេរ 4ខ្ទង់<br>● 9x9 (គុណនឹង6 ដល់9)<br>● លេខ2 និង3 ខ្ទង់ x 1ខ្ទង់(មិនសរសេរទេ)<br>● វិធីចែកដែលនៅសល់ | ● វិធីបូកដកលេខ៥ខ្ទង់<br>● វិធីគុណលេខ (3, 4ខ្ទង់)x(1ខ្ទង់), (3ខ្ទង់)x(2ខ្ទង់)<br>● វិធីចែកលេខ (3ខ្ទង់, 4ខ្ទង់) / (1ខ្ទង់)<br>● វិធីគណនាដោយមានបូកដកគុណចែក | ● វិធីគុណលេខ (4ខ្ទង់)x(2ខ្ទង់)<br>● វិធីចែកលេខ (3ខ្ទង់, 4ខ្ទង់) / (2ខ្ទង់)<br>● វិធីធ្វើលេខដោយប្រើម៉ាស៊ីនកាស៊ីអូ<br>● វិធីធ្វើលេខដោយមាន (  ) | |
| | ● អត្ថន័យនៃប្រភាគងាយស្រួល (1/2. 1/4) | ● សរសេរនិងអានប្រភាគ (1/2, 1/4, 3/4) | ● ភាគបែង ភាគយក<br>● ការប្រៀបធៀបលេខប្រភាគដែលមានភាគបែងដូចគ្នា (ភាគបែងគឺ2, 4, 8) | ● ការប្រៀបធៀបប្រភាគដែលមានភាគបែងស្មើគ្នា<br>● ប្រភាគដែលមានតម្លៃស្មើគ្នា (ភាគបែង 2, 4, 8)<br>● អត្ថន័យនៃលេខក្រោមសូន្យ(ខ្ទង់ទី១ក្រោមសូន្យ)<br>● ការប្រៀបធៀបលេខក្រោមសូន្យ<br>● វិធីបូកដកលេខក្រោមសូន្យ | ● វិធីបូកដកប្រភាគដែលមានភាគបែងស្មើគ្នា<br>● វិធីគុណចែកប្រភាគ នឹងលេខគត់<br>● បន្ថយប្រភាគ<br>● ប្រភាគចម្រុះ, ប្រភាគមិនត្រឹមត្រូវ<br>● ទស្សនៈស្តីពីលេខក្រោម0(ខ្ទង់ទី2 ក្រោមសូន្យ)<br>● វិធីគុណលេខក្រោមសូន្យ (ខ្ទង់ក្រោមសូន្យ) x (លេខគត់) | ● វិធីបូកដកប្រភាគដែលមានភាគបែងខុសគ្នា<br>● វិធីគុណប្រភាគ (ប្រគាត x ប្រភាគ)<br>● វិធីធ្វើលេខប្ាគចម្រុះ<br>● ទស្សនៈស្តីពីលេខក្រោមសូន្យ(3ខ្ទង់)<br>● វិធីបូកដកគុណចែកលេខក្រោមសូន្យ |
| | | | | ● រូបមន្តបូកនិងដក រួមទាំងលេខមិនប្រាកដ(□) | ● រូបមន្តបូកដកគុណចែក រួមទាំងលេខមិនប្រាកដ(□) | ● វិធីបូកដករូបមន្តដែលមានអក្សរ |
| រាងធរណីមាត្រ | ● ចំណុច, បន្ទាត់ត្រង់, បន្ទាត់បត់<br>● ពិនិត្យរូវ2D(បួនជ្រុងស្មើ, បួនជ្រុងទ្រវែង, ត្រីកោណ, រង្វង់)<br>● ពិនិត្យមើលរូប3Dនៅជុំវិញខ្លួន | ● បន្ទាត់, អង្កត់<br>● រាងគូប, សូលីដចតុកោណ, រាងស៊ីឡាំង | ● ពហុកោណ, ពហុកោណស្មើ<br>● លក្ខណៈពិសេសនៃបួនជ្រុងស្មើ បួនជ្រុងទ្រវែង<br>● ពីរ៉ាមីដការ៉េ, កោណ<br>● រូបបន្លាយ | ● ការគូររូបធរណីមាត្រ 2D<br>● គូររូបមុំ<br>● គូររូបបន្ទាត់ប៉ារ៉ាឡែល | ● មុំស្រួច, មុំ90˚, មុំលើស90˚<br>● ត្រីកោណស្មើ, ត្រីកោណអ៊ីសូសែល, ត្រីកោណមានមុំ90˚<br>● លក្ខណៈពិសេសនៃរង្វង់ | ● គូររូបកន្លះបន្ទាត់ពុះស្មើ មុំ ត្រីកោណ<br>● លក្ខណៈពិសេសនៃព្រីស ស៊ីឡាំង សាជីជ្រុង កោណ |
| ការវាស់វែង/ការប្រៀបធៀប | ● ប្រៀបធៀបប្រវែង(ប្រៀបធៀបផ្ទាល់, មិនកំណត់)<br>● ប្រៀបធៀបទម្ងន់ (ជញ្ជីង)<br>● ប្រៀបធៀបបរិមាណ(ប្រៀបធៀបប្រយោល,ឯកតាមិនកំណត់)<br>● ប្រៀបធៀបទំហំ(ប្រៀបធៀបផ្ទាល់) | ● ឯកតាប្រវែង (m)<br>● ឯកតាទម្ងន់(kg)<br>● ឯកតាបរិមាណ(L) | ● ឯកតាប្រវែង (cm, dm)<br>● ប្រវែងរង្វង់បួនជ្រុងទ្រវែង បួនជ្រុងស្មើ<br>● ឯកតាទម្ងន់(g)<br>● ឯកតាបរិមាណ(mL) | ● ឯកតាប្រវែង(km, mm)<br>● ទំហំនៃមុំ | ● ការប្តូរឯកតាប្រវែង, ទម្ងន់, បរិមាណ (រួមទាំងក្រោមសូន្យ)<br>● មាត្រដ្ឋានផែនទី, ការវាស់វែងចម្ងាយ | ● គណនាល្បឿនមធ្យម ផ្លូវ ម៉ោង<br>● បូកសរុបនៃមុំខាងក្នុងត្រីកោណ<br>● រូបមន្តផ្ទៃបួនជ្រុងស្មើ បួនជ្រុងទ្រវែង ត្រីកោណ |
| | ● វិធីមើលម៉ោង(ម៉ោង)<br>● ប្រតិទិន (ថ្ងៃ, អាទិត្យ, ខែ, ឆ្នាំ) | ● វិធីមើលម៉ោង(ម៉ោង, នាទី, វិនាទី) | ● កាលវិភាគ, តារាងពេលវេលា | ● ការប្តូរឯកតា(ម៉ោង, នាទី, វិនាទី)<br>● វិធីបូក-ដកម៉ោង | ● ធៀប, ភាគរយ% | ● ធៀប, គណនាអត្រា និងភាគរយ% |
| ការប្រើទិន្នន័យ | ● រៀបចំនិងបែងចែកវត្ថុនៅជុំវិញខ្លួន | ● រូបក្រាហ្វិកស្រួលៗ | ● រូបក្រាហ្វិកស្រួលៗ | ● ទិន្នន័យនិងតារាង | ● ក្រាហ្វិកបន្ទាត់បត់, ក្រាហ្វិកដំបង, ក្រាហ្វិកមូល | ● លំហាត់ប្រើតារាងនិងក្រាហ្វិក |

## ចំណុចដែលត្រូវប្រយ័ត្នក្នុងការណែនាំអំពីលេខ និងគណិត

### ● លេខខ្មែរ និង លេខបារាំង

នៅកម្ពុជា ឆ្នាំទី1 គេបង្រៀនតែលេខខ្មែរទេ ដល់ឆ្នាំទី2 ទើបបង្រៀនលេខបារាំង។ ហេតុនេះហើយ ក្នុងករណីដែលជាមានសិស្សមកចូលឆ្នាំទី2 នៅជប៉ុន អាចមានអ្នកដែលមិនចេះសរសេរឬអានលេខបារាំងក៏មាន។ ក្រៅពីនេះ ក្នុងករណីដែលប្រើលេខបារាំងដែលមានពី៤ខ្ទង់ឡើងទៅ តាមធម្មតានៅកម្ពុជា គេមានក្បៀសរាល់៣ខ្ទង់ ដូច្នេះនៅជប៉ុន ចាំបាច់ត្រូវណែនាំដោយកុំប្រើក្បៀស។

### ● ពេលសិក្សាអំពីវិធីបូកនិងវិធីដកតាមរយៈការសរសេរ

នៅជប៉ុន នៅឆ្នាំទី2 គេបង្រៀនឱ្យចេះបូក និងដកតាមរយៈការសរសេរ។ តែនៅកម្ពុជា គេមិនទាន់បង្រៀនទេ ទាល់តែចូលឆ្នាំទី3 ទើបបង្រៀន(នៅឆ្នាំទី2 គេមិនបង្រៀនតាមរយៈការសរសេរទេ)។ ដូច្នេះ សិស្សដែលចូលរៀនឆ្នាំទី2 ឬទី3 ត្រូវបង្រៀនជាមុន ឱ្យចេះធ្វើលេខបូក និងដកតាមរយៈការសរសេរ។

### ● ពេលសិក្សា 9x9

នៅជប៉ុន សិស្សឆ្នាំទី2 ត្រូវរៀនតារាងលេខគុណ9x9 រហូតដល់គុណនឹង 9។ តែនៅកម្ពុជា នៅឆ្នាំទី2 គេបង្រៀនលេខគុណត្រឹមតែគុណនឹង 2 ដល់គុណនឹង5 ហើយគុណនឹង10 ប៉ុណ្ណោះ។ ទាល់តែឆ្នាំទី3 ទើបបង្រៀនអំពីការគុណនឹង 6 ដល់ 9។ ដូច្នេះ មុននឹងចូលឆ្នាំទី3 ត្រូវបង្រៀនឱ្យចេះគុណនឹង 6 ដល់ 9 ជាមុនសិន។

©2024 Japan International Cooperation Agency. All Rights Reserved

# វប្បធម៌សាលានៅកម្ពុជា

## ព្រឹត្តិការណ៍នានានៅសាលាក្នុងមួយឆ្នាំ

ខែ10 ខែ11 ខែ12 ខែ1 ខែ2 ខែ3 ខែ4 ខែ5 ខែ6 ខែ7 ខែ8 ខែ9

ឆមាសទី1 → ឆមាសទី2

- ខែ10: ឆ្នាំសិក្សាថ្មី (※1)
- ប្រឡងឆមាស
- វិស្សមកាល(※2) (ប្រហែល2អាទិត្យ)
- ប្រឡងឆមាស
- វិស្សមកាល (ប្រហែល2ខែ)

(※1) នៅឆ្នាំ2021 និង2022 ដោយសារការរាតត្បាតនៃជម្ងឺកូវិឌ១៩ សាលាត្រូវបានបិទ ឬម៉ោងសិក្សាត្រូវបានកាត់បន្ថយ ដូច្នេះឆ្នាំសិក្សាថ្មីបានចាប់ផ្ដើមពីខែមករា។
(※2) ចំពេលចូលឆ្នាំខ្មែរ។

## លំហូរក្នុងមួយថ្ងៃ

- ថ្នាក់រៀនមានពីថ្ងៃចន្ទដល់ថ្ងៃសៅរ៍ ហើយសម្រាកថ្ងៃអាទិត្យ និងថ្ងៃបុណ្យ។
- បន្ទប់រៀននិងគ្រូមានមិនគ្រប់គ្រាន់ទេ។ ដូច្នេះហើយ សាលាខ្លះបែងចែកជា២វេន គឺវេនព្រឹក និងវេនល្ងាច។ ក៏ប៉ុន្តែបច្ចុប្បន្ននេះ សាលាដែលចែកជា២វេនមានការចុះថយ។

**ឧទាហរណ៍ សាលាបឋមសិក្សា ចែកជា២វេន**

- 7:00 ចាប់ផ្ដើមរៀនពេលព្រឹក
  - ・40នាទី×5វគ្គ
  - ・សម្រាក15នាទី×2ដង
- 11:00 ម៉ោងចប់ពេលព្រឹក
- 13:00 ចាប់ផ្ដើមរៀនពេលរសៀល
  - ・40នាទី×5វគ្គ
  - ・សម្រាក15នាទី×2ដង
- 17:00 ម៉ោងចប់ពេលល្ងាច

ស្ដីពីវិធីធ្វើដំណើរ ពុំមានសេចក្ដីណែនាំច្បាស់លាស់ទេ។ នៅស្រុកស្រែចំការ សិស្សភាគច្រើន ដើរទៅសាលា។ រីឯនៅក្រុងវិញ សិស្សខ្លះជិះកង់ សិស្សខ្លះ អ្នកអាណាព្យាបាលជូនម៉ូតូទៅសាលា។

ម៉ោងសិក្សាក្នុងមួយឯកតា សម្រាប់បឋមសិក្សាគឺ 40នាទី(1ថ្ងៃ 5វគ្គ), សម្រាប់អនុវិទ្យាល័យគឺ 50នាទី(1ថ្ងៃ 4～7វគ្គ)។

តាមរយ:ជំនួយរបស់រដ្ឋភិបាល ឬអង្គការផែនការស្បៀងអាហារពិភពលោក(WFP) សាលាមួយចំនួន មានការផ្ដល់អាហារពេលព្រឹក ក៏ប៉ុន្តែភាគច្រើន ពុំមានទេ។ បាយថ្ងៃត្រង់ ច្រើនតែត្រឡប់ទៅផ្ទះញ៉ាំ។

ជាគោលការណ៍ មានលំហាត់ទៅផ្ទះរាល់ថ្ងៃ ក៏ប៉ុន្តែ ពេលវិស្សមកាល ពុំមានលំហាត់ទេ។ ក្រោយបញ្ចប់ការសិក្សារាល់ថ្ងៃ មានសិស្សខ្លះទៅរៀនគួរដោយមានការបង់ប្រាក់ពីគ្រូទទួលបន្ទុកក្នុងថ្នាក់ក៏មានដែរ។

## វិន័យនិងទម្លាប់នៅសាលា

- នៅសាលាបឋមសិក្សា សិស្សចែកវេនគ្នាសំអាតបង្គន់ និងថ្នាក់រៀន។ នៅអនុវិទ្យាល័យ គេឱ្យក្រុមហ៊ុនម៉ៅការធ្វើការសំអាត។
- នៅម៉ោងទីមួយ មុននឹងចាប់ផ្ដើមរៀន ត្រូវគោរពទង់ជាតិ។
- ស្ដីពីវិន័យ ដូចជាម៉ូដសក់ ការប្រើគ្រឿងសំអាងកាយ គ្រឿងអលង្ការជាដើម គឺសាលានីមួយៗជាអ្នកកំណត់។
- គេអនុញ្ញាតឱ្យយកនំទៅសាលា ឬទិញនំក្នុងសាលាញ៉ាំនៅពេលសម្រាក។

## របស់ដែលចាំបាច់ក្នុងសាលា

- សាលារដ្ឋមិនយកថ្លៃសាលាទេ តែមានការចាំបាច់ទិញឯកសណ្ឋាន សៀវភៅសិក្សា ប្រដាប់ប្រដារសរសេរ ជាដើម។
- សាលាឱ្យខ្ចីសៀវភៅសិក្សា។ សាលាខ្លះឱ្យខ្ចីនៅដើមឆ្នាំសិក្សា ហើយសងវិញនៅចុងឆ្នាំសិក្សា។ ក៏បន្តែ មានសាលាខ្លះឱ្យខ្ចីរាល់ពេលរៀន ហើយសងវិញរាល់ពេលរៀនចប់។

## សកម្មភាពក្រៅពីការរៀនសូត្រ

- ពុំមានកម្មវិធីកីឡាសម្រាប់សាលានីមួយៗទេ។ ក៏ប៉ុន្តែមានកម្មវិធីប្រកួតកីឡាក្នុងសហគមន៍ ឬ ថ្នាក់ខេត្ត ឬថ្នាក់ជាតិ។ កម្មវិធីដើរលេង ឬកម្មវិធីទស្សនកិច្ចបញ្ចប់ការសិក្សា មានតែសាលាមួយចំនួនតូចទេដែលមាន។

## ពាក់ព័ន្ធនឹងអ្នកអាណាព្យាបាល

- ពុំមានថ្ងៃសម្រាប់អ្នកអាណាព្យាបាលទៅមើលសិស្សរៀនទេ។ ក៏ប៉ុន្តែអ្នកអាណាព្យាបាលអាចទៅសាលា ឬទៅថ្នាក់មើលបាន។ មានការជួបជាមួយអ្នកអាណាព្យាបាលទៀងទាត់។ តែពុំមានកម្មវិធីឱ្យគ្រូទៅផ្ទះសិស្សទេ។ ក៏ប៉ុន្តែ ចំពោះសិស្សដែលមានបញ្ហា ជួនកាលគ្រូទៅសួរដល់ផ្ទះក៏មានដែរ។
- ស្ដីពីលទ្ធផលនៃការប្រឡងមួយខែម្ដង មានសរសេរនៅក្នុងកូនសៀវភៅកំណត់សិក្សា ហើយគេប្រគល់ឱ្យអ្នកអាណាព្យាបាលដើម្បីឱ្យអ្នកអាណាព្យាបាលសរសេរចំណាប់អារម្មណ៍ ហើយសងទៅសាលាវិញ។

## ចំណុចដែលត្រូវប្រយ័ត្នក្នុងការណែនាំ

- នៅកម្ពុជា គេអនុញ្ញាតឱ្យយកនំទៅញ៉ាំនៅសាលា ឬទិញនំនៅក្នុងសាលាញ៉ាំពេលសម្រាកបាន។ តែនៅជប៉ុន គេមិនអនុញ្ញាតទេ ដូច្នេះ អាចមានករណីដែលត្រូវប្រាប់អាណាព្យាបាល ឬសិស្ស។

©2024 Japan International Cooperation Agency. All Rights Reserved